សុន្ទរកថារបស់**លោក ហ៊ីហ្គេឌិ យ៉ូស៊ីហ៊ីរ៉ូ** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២០ កុម្ភៈ ២០១៣

**សូមគោរព លោក ចាប កុយ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះជាមួយមន្ទីរធនធានទឹក និង ឧតុនិយមខេត្តព្រះវិហារសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពប្រាសាទនាគបួសក្នុងខេត្តព្រះវិហារ។ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាពិសេសដោយពិធីនេះត្រូវបានប្រារព្ធឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ដែលជាខួបលើកទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅបង្កើនផលិតកម្មកសិកម្មក្នុងស្រុកជាំក្សាន្តដោយពង្រីកនូវផ្ទៃដីស្រោចស្រពតាមរយៈការស្តារទំនប់អាងស្តុកទឹកប្រវែង៩០០ម៉ែត្រ និង ប្រឡាយរងប្រវែង៨០០ម៉ែត្រ។ នៅក្នុងគម្រោងនេះដែរ សំណង់បញ្ចេញទឹក១កន្លែង សំណង់ស្ទាក់ទឹក១កន្លែង និងផ្លូវបង្ហៀរទឹកដែលចាំបាច់សម្រាប់ប្រព័ន្ធធារាសាស្ត្រនេះក៏នឹងត្រូវបានសាងសង់ផងដែរ។ ថវិកាដែលត្រូវផ្តល់ជូនក្នុងគម្រោងនេះមានទឹកប្រាក់សរុបចំនួន ១០០,១០០ដុល្លាអាមេរិក។ យើងរំពឹងថា គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ៣០០គ្រួសារដែលនឹងប្រើប្រាស់ប្រព័ន្ធស្រោចស្រពនេះដើម្បីបង្កើនទិន្នផលដំណាំជាបន្តបន្ទាប់។

ការអភិវឌ្ឍន៍វិស័យកសិកម្ម ជាពិសេសការបង្កើនទិន្នផលស្រូវជាគោលដៅអាទិភាពមួយសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជាដែលរាជរដ្ឋាភិបាលកម្ពុជាបាន និង កំពុងបន្តពង្រីក និងស្តារប្រព័ន្ធធារាសាស្ត្រយ៉ាងសកម្មនៅទូទាំងប្រទេស។ ការបង្កើនផលិតកម្មស្រូវនឹងជួយបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករក៏ដូចជាកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។

ដោយទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ចរបស់កម្ពុជា រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការស្តារប្រព័ន្ធធារាសាស្ត្រ ក៏ដូចជាការផ្ទេរនូវបច្ចេកទេសធ្វើកសិកម្មជាដើម។ គម្រោងនេះធ្វើឡើងតាមគោលការណ៍នៃយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្តល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថា គម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដោយដៃគូរបស់យើងគឺមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារ ដើម្បីប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណ!